អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres extraordinaires au sein des tribunaux cambodgiens

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

ថ្ងៃទី១៦ ខែសីហា ឆ្នាំ២០១០

# សេចក្តីថ្លែងការណ៍របស់សហព្រះរាជអាជ្ញា

ថ្ងៃនេះ សហព្រះរាជអាជ្ញា បានដាក់ដីកាសន្និដ្ឋានស្ថាពររបស់ខ្លួន នៅក្នុងសំណុំរឿងលេខ០០២ ទៅ សហចៅក្រមស៊ើបអង្កេត អនុលោមតាមវិធាន ៦៦.៥ នៃវិធានផ្ទៃក្នុងសម្រាប់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (អ.វ.ត.ក) នៅពេលសហព្រះរាជអាជ្ញាពិចារណាឃើញថា កិច្ចស៊ើបសួរត្រូវបានបញ្ចប់ សហព្រះរាជអាជ្ញាតម្រូវឲ្យធ្វើដីកាសន្និដ្ឋានស្ថាពរមួយជាលាយល័ក្ខអក្សរ និងមានសំអាងហេតុក្នុងថិរវេលា៤៥ (សែសិបប្រាំ) ថ្ងៃ គិតចាប់ពីថ្ងៃទទួលបានសំណុំរឿងពីសហចៅក្រមស៊ើបអង្កេត។ ដើម្បីពន្លឿនដល់ដំណើរការច្បាប់ សហព្រះរាជអាជ្ញា បានដាក់ដីកាសន្និដ្ឋានស្ថាពររបស់ខ្លួន ឲ្យបានឆាប់បន្តិចមុនកាលកំណត់ តាមអាណត្តិដូចមានចែងនៅក្នុងវិធានផ្ទៃក្នុង។

នៅក្នុងដីកាសន្និដ្ឋាននេះ សហព្រះរាជអាជ្ញាស្នើថា គេត្រូវធ្វើការចោទប្រកាន់ និងត្រូវបញ្ជូនជនត្រូវចោទ៖ **នួន ជា អៀង សារី ខៀវ សំផន** និង **អៀង ធីរិទ្ធ** ទៅធ្វើការកាត់សេចក្តីចំពោះឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ អំពើបំពានបំពានយ៉ាងធ្ងន់ធ្ងរទៅលើអនុសញ្ញាទីក្រុងហ្សឺណែវ និងការរំលោភទៅលើក្រមព្រហ្មទណ្ឌកម្ពុជាឆ្នាំ១៩៥៦ ។ សហព្រះរាជអាជ្ញាជឿជាក់ថា ភស្តុតាងដែលប្រមូលបាននៅក្នុងការស៊ើបសួរ បានបង្ហាញថា ជនត្រូវចោទទាំងនេះបានប្រព្រឹត្តនូវបទឧក្រិដ្ឋនានា តាមរយៈសហកម្មឧក្រិដ្ឋកម្មរួមមួយ ដែលមានគោលបំណងដាក់ឲ្យប្រតិបត្តិនូវបដិវត្តនយោបាយមួយនៅក្នុងប្រទេសកម្ពុជា និងដើម្បីធ្វើការកម្ទេចជាប្រព័ន្ធនូវពួកប្រឆាំងណាក៏ដោយ ដែលជំទាស់ទៅនឹងការកាន់អំណាចរបស់បក្សកុម្មុយនីសកម្ពុជា។ តាមរយៈសហកម្មឧក្រិដ្ឋកម្មរួមនេះ ជនត្រូវចោទទាំងនេះ បានធ្វើឲ្យប្រជាជនកម្ពុជាក្លាយទៅជាទាសករ បានដកហូតនូវសិទ្ធិមនុស្ស និងសេរីភាពជាមូលដ្ឋាននានារបស់ប្រជាជន ព្រមទាំងបានធ្វើការសម្របសម្រួលនូវការសម្លាប់រង្គាលទៅលើបុគ្គលនានា ដែលជនត្រូវចោទទាំងនេះ និងពួកមេដឹកនាំបក្សកុម្មុយនីស្តកម្ពុជាដទៃទៀត យល់ឃើញថាជាខ្មាំងពិតប្រាកដ ឬជាខ្មាំងសក្តានុពលនៃបក្សកុម្មុយនីសកម្ពុជា។

ឯកសារដាក់ជូននូវសេចក្តីសង្ខេបមួយដ៏ទូលំទូលាយ (ចំនួន៩៣១ទំព័រ) អំពីអង្គហេតុពាក់ព័ន្ធ ដែលគាំទ្រចំពោះការចោទប្រកាន់ទាំងឡាយរបស់សហព្រះរាជអាជ្ញា ដែលត្រូវបានកំណត់ជាបទចោទស្របទៅតាមច្បាប់ដោយទាំង

ឧក្រិដ្ឋកម្មនានាដែលបានប្រព្រឹត្តផង និងទាំងលក្ខណៈនៃឧក្រិដ្ឋកម្មអំពីការចូលរួមរបស់ជនត្រូវចោទទាំងនេះនៅក្នុងឧក្រិដ្ឋកម្មទាំងនោះផង។ បទចោទដែលបានលើកឡើងជាអនុសាសន៍របស់សហព្រះរាជអាជ្ញា ត្រូវបានគាំទ្រដោយឯកសារភស្តុតាងចំនួនជាង២៨០០ឯកសារ ដែលរួមមានកំណត់ហេតុនៃចម្លើយសាក្សី ជនត្រូវចោទ និងអ្នកជំនាញនានា ព្រមទាំងឯកសារនានាពីសម័យនៃរបបកម្ពុជាប្រជាធិបតេយ្យ និងបក្សកុម្មុយនីស្តកម្ពុជា។ ឯកសារជាច្រើនក្នុងចំណោមឯកសារទាំងនេះ ត្រូវបានមជ្ឈមណ្ឌលឯកសារកម្ពុជាធ្វើជាបណ្ណសារ និងជាសៀវភៅកាតាឡុក។ ពាក្យសុំរបស់ដើមបណ្តឹងរដ្ឋប្បវេណី និងពាក្យបណ្តឹងរបស់ជនរងគ្រោះនានា ក៏ត្រូវបានពឹងផ្អែកធ្វើជាមូលដ្ឋាននៅក្នុងដីកាសន្និដ្ឋាននេះដែរ។

សហចៅក្រមស៊ើបអង្កេត បានបំបែកសំណុំរឿងប្រឆាំងនឹង **កាំង ហ្កេកអ៊ាវ** *ហៅ* **ឌុច** នៅថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០០៧ តាមរយៈការសម្រេចបំបែកកិច្ចស៊ើបសួរ លើការទទួលខុសត្រូវរបស់គាត់ចំពោះ “អង្គហេតុនានាដែលបានប្រព្រឹត្តឡើងក្នុងក្របខ័ណ្ឌ ស-២១” (សំណុំរឿងលេខ ០០១) ។ ដូចដែល ឌុច នៅតែត្រូវបានចោទប្រកាន់នៅក្នុងសំណុំរឿង០០២ សហព្រះរាជអាជ្ញា បានស្នើសុំឲ្យធ្វើការលើកលែងការចោទប្រកាន់ប្រឆាំងនឹងរូបគាត់។ សហព្រះរាជអាជ្ញា យល់ឃើញថា ការចោទប្រកាន់ប្រឆាំងនឹងរូបគាត់អំពីឧក្រិដ្ឋកម្មនានា ដែលត្រូវបានប្រព្រឹត្តនៅខាងក្រៅក្របខ័ណ្ឌមន្ទីរសន្តិសុខស-២១នោះ វាមិនមែនជាផលប្រយោជន៍ដល់យុត្តិធម៌ទេ។ ក្នុងការធ្វើសំណើសុំនេះ សហព្រះរាជអាជ្ញាបានគិតគូរយកចិត្តដាក់យ៉ាងពេញលេញទៅលើប្រការដែលថា ដំណើរការដ៏វែងនៃនីតិវិធីព្រហ្មទណ្ឌ ត្រូវបានធ្វើសេចក្តីសន្និដ្ឋានរួចហើយប្រឆាំងនឹង ឌុច នៅក្នុងការកាត់ឲ្យគាត់ជាប់ទោសក្នុងពេលថ្មីៗនេះនៅក្នុងសំណុំរឿងលេខ ០០១។ សហព្រះរាជអាជ្ញាជឿថាការដក ឌុច ចេញពីក្នុងសំណុំរឿងលេខ០០២ មុខជានឹងជួយនៅក្នុងការធ្វើឲ្យមានភាពប្រាកដប្រជាដល់ការសវនាការដ៏ត្រឹមត្រូវនិងយ៉ាងឆាប់រហ័សរបស់ **នួន ជា អៀង សារី ខៀវ សំផន អៀង ធីរិទ្ធ** ដែលការទទួលខុសត្រូវខាងព្រហ្មទណ្ឌរបស់ពួកគេចំពោះឧក្រិដ្ឋកម្មទាំងនោះដែលបានកើតឡើងនៅក្នុងសម័យកាលនៃកម្ពុជាប្រជាធិបតេយ្យ នៅមិនទាន់ត្រូវបានធ្វើការកាត់សេចក្តីនៅឡើយ។

ដោយទទួលស្គាល់អំពីសារសំខាន់ជាប្រវត្តិសាស្ត្រនៃសំណុំរឿងនេះ និងអំពីតម្រូវការដើម្បីធានាឲ្យប្រាកដថាសាធារណជន បានជ្រាបត្រឹមត្រូវអំពីកិច្ចដំណើរការនីតិវិធីដែលកំពុងតែបន្ត នៅចំពោះមុខ អ.វ.ត.ក សហព្រះរាជអាជ្ញា នឹងផ្តល់ជូនដល់សាធារណជនក្នុងពេលឆាប់ៗខាងមុខនេះ នូវសេចក្តីសង្ខេបអំពីគោលបំណងនៃដីកាសន្និដ្ឋានស្ថាពររបស់ខ្លួន ស្របតាមវិធាន៥៤ នៃវិធានផ្ទៃក្នុង៕

-----------------------------------------